**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១១២.០៥៣/០៧ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧

# គ.ជ.ប ឆ្លើយតបទៅគណបក្សសិទ្ធិមនុស្ស

នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៧ គណបក្សសិទ្ធិមនុស្ស បានដាក់ពាក្យប្ដឹងមក គ.ជ.ប ដើម្បីឱ្យ គ.ជ.ប ជួយអន្តរាគមន៍តាមផ្លូវច្បាប់ និងរកយុត្តិធម៌ អំពីការវាយកំទេចបំផ្លាញទំលាក់ស្លាកគណបក្សសិទ្ធិមនុស្សជាបន្តបន្ទាប់ នៅសួនច្បារផ្សារចាស់ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចំនួន ១ លើក នៅក្នុងសង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន ចំនួន ១ លើក នៅរោងកុនហែមជាតិ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ចំនួន ២ លើក នៅគល់ស្ពានព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ចំនួន ១ លើក និងនៅមុខវត្តចិនដំដែក សង្កាត់ស្រះចក ខណ្ឌដូនពេញ ចំនួន ១ លើក ។

នៅក្នុងលិខិតឆ្លើយតបរបស់ គ.ជ.ប ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ផ្ញើជូនគណបក្សសិទ្ធិមនុស្សសរសេរថា គ.ជ.ប បានពិនិត្យលើពាក្យបណ្ដឹងយ៉ាងយកចិត្តទុកដាក់ ហើយឃើញថា បណ្ដឹងនេះ មិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់ គ.ជ.ប ដូចមានក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះទេ ។ ដូច្នេះ គ.ជ.ប មិនអាចទទួលយកពាក្យបណ្ដឹងនេះមកដោះស្រាយបានឡើយ ។ គ.ជ.ប បានសូមឱ្យគណបក្សអនុវត្តតាមបទបញ្ញត្តិដូចមានចែងក្នុងច្បាប់ ស្ដីពីគណបក្សនយោបាយ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា ជាធម្មតាតាំងពីមុនដំណើរការរៀបចំការបោះឆ្នោត គ.ជ.ប បានសហការជាមួយក្រសួងមហាផ្ទៃ ក៏ដូចអាជ្ញាធរដែនដី ដើម្បីបង្កលក្ខណៈជូនគណបក្សនយោបាយ ធ្វើសកម្មភាពស្របច្បាប់ តាមច្បាប់ស្ដីពីគណបក្សនយោបាយ ។